# III. ផ្នែកទីស្តីការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

*រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៤*

### អនុក្រឹត្យលេខ ៣២ អនក្រ

### ស្តីពីការកំណត់រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ ឃុំ សង្កាត់

---

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ :-** រៀបចំរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ ឃុំ មានដូចខាងក្រោមនេះ ៖

១- មេឃុំ

២- ជំទប់លេខ ១

៣- ជំទប់លេខ ២

៤- ជំទប់លេខ៣

៥- ជំនួយការរដ្ឋបាលឃុំ ចំនួន មួយរូប ។

៸

មាត្រា ២ : រៀបចំរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់សង្កាត់ មានដូចខាងក្រោមនេះ ៖

១- ចៅសង្កាត់

២- ចៅសង្កាត់រងទី ១

៣- ចៅសង្កាត់រងទី ២

៤- ជំនួការរដ្ឋបាលសង្កាត់ចំនួន ២ រូប ។

មាត្រា ៣ : ភូមិគឺជាចំណែកមួយនៃឃុំ ឬ សង្កាត់ និង ជារចនាសម្ព័ន្ធជំនួយការរដ្ឋបាលថ្នាក់ឃុំ សង្កាត់ ដែលគ្រប់គ្រងដោយមេភូមិ ។

មាត្រា ៤ : តួនាទីភារកិច្ចជាក់ស្តែង នៃរចនាសម្ព័ន្ធរដ្ឋបាល ថ្នាក់ឃុំ សង្កាត់ និង ការបែងចែកភារកិច្ចជូនមន្ត្រី ឃុំសង្កាត់ ដែលមានស្រាប់ទៅតាមរចនាសម្ព័ន្ធនេះ អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអ្នកកំណត់ណែនាំ ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់គ្រង រដ្ឋលេខាធិការដ្ឋានត្រូវទទួលបន្ទុកអនុវត្តអនុក្រិត្យតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |